សាកលវិទ្យាល័យ
អាយអាយស៊ី
នៃបច្ចេកវិទ្យា
IIC UNIVERSITY OF TECHNOLOGY

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## សារណាសម្រាប់បំពេញលក្ខណថ្នាក់បរិញ្ញាបត្រ
## មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម
## ជំនាន់ទី ១៤ ជំនាញ រដ្ឋបាលសាធារណៈ
## " ការគ្រប់គ្រងរដ្ឋបាលសាលាខណ្ឌទួលគោក នៃរាជធានីភ្នំពេញ "


រៀបរៀងដោយក្រុមនិសិត្ស

| | | | |
|---|---|---|---|
| វ៉សេត វ៉ស់ម៉ាន | អត្តលេខ | CB127634 | ប្រធាន |
| លេង សីឡា | អត្តលេខ | CB127733 | សមាជិក |
| វង្ស សារ៉ុន | អត្តលេខ | CB127729 | សមាជិក |
| អ៊ុំ ផាណុង | អត្តលេខ | CB127724 | សមាជិក |
| អ៊ុយ សុទី | អត្តលេខ | CB127683 | សមាជិក |
| គង់ សុជាតិ | អត្តលេខ | CB127573 | សមាជិក |

សាស្ត្រាចារ្យណែនាំ
លោក សាស្ត្រាចារ្យ កេត ឧត្តម


ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០១៥

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ សេចក្តីផ្តើម

យោងតាមមាត្រា ៤ នៃច្បាប់ស្តីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ ២០០៨ បានកំណត់ថា ភ្នំពេញជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា។ រាជធានីភ្នំពេញចែកជាខណ្ឌ ខណ្ឌចែកជាសង្កាត់។

រាជធានីភ្នំពេញបានចែងចែកជា ១២ខណ្ឌមានដូចជា ខណ្ឌ៧មករា ខណ្ឌមានជ័យ ខណ្ឌសែនសុខ ខណ្ឌពោធិ៍សែនជ័យ ខណ្ឌដង្កោ ខណ្ឌឬស្សីកែវ ខណ្ឌចំការមន ខណ្ឌដូនពេញ ខណ្ឌជ្រោយចង្វា ខណ្ឌច្បារអំពៅ ខណ្ឌព្រែកព្នៅ និងខណ្ឌទួលគោក។

## ១.២ បុព្វហេតុនៃការសិក្សាស្រាវជ្រាវ

មានកត្តាចម្បងមួយចំនួនដែលជាបុព្វហេតុនាំឱ្យមានការសិក្សាស្រាវជ្រាវ បុព្វហេតុទាំងនោះរួមមាន÷

- ការសម្រេចចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា អនុវត្តប្រព័ន្ធវិមជ្ឈការឡើងវិញ ក្រោយពីទទួលសុខសន្តិភាពស្ថេរភាពនយោបាយចាប់តាំងពីឆ្នាំ១៩៩៣មក
- គោលការណ៍ អភិបាលកិច្ចល្អស្តីពីកំណែទម្រង់រដ្ឋបាលសាធារណៈនៅកម្ពុជា។
- ការបោះឆ្នោតជ្រើសរើសអ្នក តំណាងតាមមូលដ្ឋានសម្រាប់ធ្វើការអភិវឌ្ឍ ហើយទទួលខុសត្រូវចំពោះប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួន។
- រាជរដ្ឋាភិបាលប្រគល់ឱ្យក្រុមប្រឹក្សា ភាពជាម្ចាស់លើមុខងារសិទ្ធិអំណាចនិងធានាដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់មូលដ្ឋានជាដើម។

## ១.៣ ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ

- តើរដ្ឋបាលមូលដ្ឋាន មានវិធីសាស្ត្របែបណាដើម្បីធ្វើឱ្យដំណើរការនៃការគ្រប់គ្រងរដ្ឋបាលមានគុណភាព និងប្រសិទ្ធភាពខ្ពស់?

- តើប្រជាពលរដ្ឋមានសកម្មភាពចូលរួម ក្នុងការអភិវឌ្ឍខណ្ឌរបស់ខ្លួនដល់កម្រិតណា? ហើយអាជ្ញាធរមានវិធីសាស្ត្របែបណាខ្លះ?
- បើសិនជាសមត្ថភាពមានកម្រិត តើការអនុវត្តន៍វិមជ្ឈការនៅក្នុងខណ្ឌទទួលបានជោគជ័យដែរឬទេ?
- តើប្រជាពលរដ្ឋទទួលបានអ្វីខ្លះពីការអនុវត្តន៍ប្រព័ន្ធវិមជ្ឈការ?

## ១.៤ គោលបំណងនៃការសិក្សាស្រាវជ្រាវ

គោលបំណងចម្បងនៃការសិក្សាស្រាវជ្រាវនេះ គឺផ្តោតទៅលើចំណុចសំខាន់ៗដូចជា÷

- សិក្សាទៅលើការគ្រប់គ្រងរដ្ឋបាលនៅខណ្ឌទួលគោក
- សិក្សាទៅលើដំណើរការផ្តល់សេវាសាធារណៈនៅសាលាខណ្ឌទួលគោក

- សិក្សាពីគោលការណ៍អភិបាលកិច្ចល្អ របស់សាលាខណ្ឌទួលគោក
- សិក្សាទៅលើគោលការណ៍នៃការអភិវឌ្ឍនៃខណ្ឌទួលគោក
- សិក្សាទៅលើសាមគ្គីភាពរវាងប្រជាពលរដ្ឋ និងរដ្ឋបាលខណ្ឌដើម្បីឈានឆ្ពោះទៅរកការអភិវឌ្ឍខណ្ឌ។
- សិក្សាពីបរិបទជុំវិញក្នុងខណ្ឌទួលគោក

## ១.៥ ទំហំ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវរបស់ក្រុមយើងខ្ញុំ គឺសិក្សាផ្តោតទៅលើការគ្រប់គ្រងរដ្ឋបាលនៃខណ្ឌទួលគោកស្ថិតនៅក្នុងរាជធានីភ្នំពេញ។ ហើយទិន្នន័យដែលក្រុមយើងខ្ញុំធ្វើការសិក្សាស្រាវជ្រាវ គឺចាប់ពីខែឧសភា ឆ្នាំ២០១៤ រហូតដល់ខែមិថុនា ឆ្នាំ២០១៥ ប៉ុណ្ណោះ។ ការដែលកំណត់នូវទំហំ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវហើយធ្វើឱ្យយើងមានភាពងាយស្រួលក្នុងការកំណត់វិធីសាស្ត្រ នៃការសិក្សាស្រាវជ្រាវ។

# ១.៦ វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

## ១.៦.១. វិធីសាស្ត្រប្រមូលទិន្នន័យ

ក. ទិន្នន័យចម្បង (Primary Data)

ខ. ទិន្នន័យបន្ទាប់បន្សំ ( Secondary Data)

## ១.៦.២ វិធីសាស្ត្រវិភាគទិន្នន័យ

នៅក្នុងការវិភាគទិន្នន័យដែលប្រមូលបាន គឺក្រុមយើងខ្ញុំបានធ្វើការវិភាគតាមបែបគុណភាពដោយផ្អែកលើការវិភាគ ភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែង ដើម្បីធ្វើការវិភាគពីដំណើរការនៃការគ្រប់គ្រងរដ្ឋបាលសាលាខណ្ឌទួលគោករាជធានីភ្នំពេញ។

# ១.៧ សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

## ១.៧.១ សារៈប្រយោជន៍សម្រាប់អ្នកស្រាវជ្រាវ

- ដើម្បីធ្វើឱ្យក្រុមយើងខ្ញុំពង្រឹងនូវចំណេះដឹងដែលបានសិក្សាកន្លងមក។
- ដើម្បីបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែករដ្ឋបាលសាធារណៈដោយជោគជ័យ។
- ដើម្បីដកស្រង់នូវបទពិសោធន៍ថ្មីៗ នៃផ្នែកទ្រឹស្ដីជាមួយនឹងការអនុវត្តន៍ជាក់ស្ដែង
- ដើម្បីបង្កើនសមត្ថភាពឱ្យបានសមស្របសម្រាប់តម្រូវការរបស់សង្គម។

## ១.៧.២ សារៈប្រយោជន៍សម្រាប់សាលាខណ្ឌទួលគោក

- កាត់បន្ថយភាពខ្វះខាតមួយចំនួន ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាលមូលដ្ឋាន។
- បំពេញបន្ថែមនូវចំណុចខ្វះខាតមួយចំនួន ដែលកើតមានក្នុងពេលអនុវត្តការងាររបស់ខណ្ឌទួលគោក។

- ដើម្បីបង្កើតនូវចំណងមិត្តភាពរវាងមន្ត្រីសាលាខណ្ឌ និស្សិត និងប្រជាពលរដ្ឋ។

**១.៧.៣ សារៈប្រយោជន៍សម្រាប់សង្គម**

- សម្រាប់ទុកជាឯកសារដល់អ្នកសិក្សាជំនាន់ក្រោយៗ ធ្វើជាជំនួយនៃការសិក្សាស្រាវជ្រាវ
- ដើម្បីបង្កើនចំណេះដឹងដល់អ្នកអានបានយល់ពីការផ្តល់សេវា របស់ខណ្ឌចំពោះពួកគាត់គ្រប់ៗរូប។
- ដើម្បីជួយដល់អ្នកអានឱ្យបានដឹងពីការគ្រប់គ្រងរដ្ឋបាលថ្នាក់មូលដ្ឋានផងដែរ។

## ១.៨ ក្របខ័ណ្ឌ នៃការសិក្សាស្រាវជ្រាវ

**ជំពូកទី១**

**ជំពូកទី ២**

១ -សញ្ញាណទូទៅរដ្ឋបាលសាធារណៈ
២ -ប្រវត្តិរដ្ឋបាលកម្ពុជា
៣-គោលការណ៍រៀបចំគ្រប់គ្រងរដ្ឋបាល
៤ -ប្រវត្តិអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា
៥ -ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស នៅរដ្ឋបាលថ្នាក់ក្រោមជាតិ
៦ -បទប្បញ្ញត្តិពិសេសសម្រាប់ក្រុមប្រឹក្សាស្រុកក្រុមប្រឹក្សាឃុំក្រុមប្រឹក្សាសង្កាត់ដែលស្ថិតក្នុងស្រុក

**ជំពូកទី ៣**

១ -ប្រវត្តិរបស់សាលាខណឌទួលគោក
២ -រចនាសម្ព័ររបស់សាលាខណ្ឌទួលគោក
៣ -ការគ្រប់គ្រងរបស់សាលាខណ្ឌទួលគោក
៤ -សេវាដែលផ្តល់ដោយសាលាខណ្ឌទួលគោក
៥ -សមិទ្ធិផលដែលខណ្ឌសម្រេចបាន
៦ -ផែនការ និងយុទ្ធសាស្រ្តសម្រាប់ធ្វើការអភិវឌ្ឍខណ្ឌទួលគោក

**ជំពូកទី ៤ ការវិភាគ និងរបកគំហើយ**

**ជំពូកទី ៥ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍**

## ១.៩ រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

- ការសិក្សាស្រាវជ្រាវនេះបែងចែកជាប្រាំជំពូករួមមានដូចខាងក្រោម÷
- ជំពូកទី១ សេចក្តីផ្តើម
- ជំពូកទី២ រំលឹកទ្រឹស្តី
- ជំពូកទី៣ ស្ថានភាពទូទៅរបស់សាលាខណ្ឌទួលគោក
- ជំពូកទី៤ ការវិភាគ និងរបកគំហើញ
- ជំពូកទី៥ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

# ជំពូកទី ២
# រំលឹកទ្រឹស្តី

# ជំពូកទី២
# រំលឹកទ្រឹស្តី

## ២.១ សញ្ញាណទូទៅរដ្ឋបាលសាធារណៈ

### ២.១.១ និយមន័យនៃពាក្យរដ្ឋបាល

មុននឹងយល់ដឹងនូវអ្វីដែលហៅថា **អំណាចរដ្ឋបាលសាធារណៈ** យើងគប្បីយល់នូវពាក្យ “ រដ្ឋបាល” “រដ្ឋបាលសាធារណៈ” ជាមុនសិន ។

ពាក្យថា “ រដ្ឋបាល ”មានប្រភពមកពីពាក្យថា “ រដ្ឋ និងបាល ” រដ្ឋ មានន័យថា បុរី ឬ នគរ។ រដ្ឋបាលមានន័យថា ជាការមើលខុសត្រូវថែរក្សា ឬការគ្រប់គ្រង ដូច្នេះយើងអាចនិយាយបានថា រដ្ឋបាលគឺជាការគ្រប់គ្រងនគរឬរដ្ឋ។

ប៉ុន្តែបើតាមអត្ថន័យទូទៅដែលជាការអនុវត្តជាក់ស្តែងនោះ រដ្ឋបាលមានអត្ថន័យសំខាន់ពីរយ៉ាង÷

ន័យជាអង្គការ សំដៅលើការគ្រប់គ្រងលើការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាព មួយ។ ឧទាហរណ៍ ក្រសួងមហាផ្ទៃ។

ន័យជា សកម្មភាពកិច្ចការរដ្ឋបាលរបស់ក្រសួង ឬស្ថាប័ន។

រដ្ឋបាល គឺជាសកម្មភាពមួយដែលបំរើការរស់នៅរាល់ថ្ងៃជាប្រចាំ ពោលគឺសកម្មភាព បម្រើប្រយោជន៍ទាំងឡាយណាដែលទាក់ទងទៅនិងការរស់នៅ ឬតម្រូវការជាប្រចាំរាល់ថ្ងៃរបស់ មនុស្សទូទៅក្នុងសង្គម។

រដ្ឋបាល មានបេសកកម្មបម្រើឱ្យផលប្រយោជន៍សាធារណៈ ហើយមានលក្ខណៈជាប្រចាំ នោះគឺមានន័យថាបម្រើផលប្រយោជន៍ក្នុងការរស់នៅជាប្រចាំរាល់ថ្ងៃ។ គេអាចឱ្យនិយមន័យជា សង្ខេបបានថា

**ក.រដ្ឋបាល** គឺជាម៉ាស៊ីនដែលប្រមូលផ្តុំចូលគ្នានូវ គោលនយោបាយ លិខិតបទដ្ឋាន នីតិវិធី ប្រព័ន្ធ រចនាសម្ព័ន្ធ អង្គការចាត់តាំងបុគ្គលិក

**ខ.ជាការគ្រប់គ្រង** និងការអនុវត្តគ្រប់ប្រភេទនៃសកម្មភាពរបស់រដ្ឋាភិបាល គឺមានការពាក់ព័ន្ធទៅនិងការអនុវត្តច្បាប់បទបញ្ញត្តិនានា និងសេចក្ដីសម្រេចចិត្តដែលធ្វើឡើងដោយរដ្ឋាភិបាល និងគ្រប់គ្រងទៅលើបញ្ញត្តិស្ដីពីសេវាសាធារណៈនានា។

**២.១.២ និយមន័យនៃពាក្យរដ្ឋបាលសាធារណៈ**

ទស្សនៈវិទូខាងច្បាប់មួយចំនួនបានឱ្យនិយមន័យ រដ្ឋបាលសាធារណៈខុសប្លែកៗពីគ្នាដូចជា÷

- តាមបែបនយោបាយរដ្ឋបាលសាធារណៈ គឺជាជំហាននៃការធ្វើគោលនយោបាយសាធារណៈដែលគ្មានដែនកំណត់។
- តាមបែបច្បាប់រដ្ឋបាលសាធារណៈជាច្បាប់ដែលកំពុងចូលជាធរមាន(កំពុងអនុវត្ត)
- តាមការគ្រប់គ្រង រដ្ឋបាលសាធារណៈជាសិល្បៈនៃការគ្រប់គ្រងនៅក្នុងរដ្ឋាភិបាល។

**២.១.៣ លក្ខណៈរបស់រដ្ឋបាលសាធារណៈ**

បាលសាធារណៈ ត្រូវបានកំណត់សម្គាល់ដោយលក្ខណៈមួយចំនួនដូចខាងក្រោម ÷

- ត្រូវបានប្រើប្រាស់នៅក្នុងក្របខ័ណ្ឌអង្គភាព ក្រសួងស្ថាប័នមន្ទីរ ការិយាល័យរបស់រដ្ឋ ។
- ការគ្រប់គ្រងមានលក្ខណៈទូលំទូលាយ
- សកម្មភាពរបស់មន្ត្រីរាជការ គឺផ្អែកលើមូលដ្ឋាន នៃទំនុកចិត្តពីសាធារណជនពោលគឺការទទួលខុសត្រូវខាងផ្លូវច្បាប់។
- នីតិក្នុងការចេញសេចក្ដីសម្រេចមានលក្ខណៈជាប្រចាំ និងជាក់លាក់
- ទទួលរងនូវការរិះគន់ពីសាធារណៈជន។

## ២.១.៤ តួនាទីរបស់រដ្ឋបាលសាធារណៈនៅក្នុងសង្គមទំនើប

ការផលិត និងការផ្គត់ផ្គង់សេវាសាធារណៈ ការការពារ និងថែរក្សាសណ្តាប់ធ្នាប់សង្គម ការការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ គឺជាតួនាទីភារកិច្ចរបស់រដ្ឋាភិបាលដែលត្រូវធ្វើតាមរយៈរដ្ឋាភិបាលសាធារណៈ។

## ២.១.៥ គោលដៅអ្នករាជការ

គោលដៅរបស់អ្នករាជការ គឺគិតគូរពីផលប្រយោជន៍ទូទៅរបស់សង្គមជាតិទាំងមូលដែលគេហៅម្យ៉ាងទៀតថា ប្រយោជន៍សាធារណៈ ដើម្បីបម្រើរាស្ត្រប្រជាឱ្យកាន់តែប្រសើរប៉ុណ្ណោះ។

អ្នករាជការស្ថិតនៅក្រោមគោលការណ៍ពីគឺ ÷

- គោលការណ៍សមភាពនៃអ្នកប្រើប្រាស់សេវាសាធារណៈ។
- គោលការណ៍និរន្តរភាពនៃសេវាសាធារណៈ ។

## ២.១.៦ បច្ចេកទេសរបស់រាជការ

ដោយសារបុព្វសិទ្ធិ នៃអំណាចសាធារណៈនេះនាំឱ្យរាជការមានសិទ្ធិប្រើប្រាស់នូវកម្លាំងសាធារណៈដូចជា កម្លាំងអាវុធហត្ថ កម្លាំងនគរបាលជាដើម។

- ឧទាហរណ៍១ ការរឹបអូស (Appropriation) លើការកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋពីសំណាក់ប្រជាពលរដ្ឋកន្លងមក ដូចជា ព្រៃក បឹង ទន្លេ សមុទ្រ ភ្នំ ដីសាធារណៈ .... ។
- ឧទាហរណ៍២ អស្សាមិករណ៍ (Expropriation) លើការយកទ្រព្យសម្បត្តិស្របច្បាប់របស់ប្រជាពលរដ្ឋមកធ្វើជាទ្រព្យសម្បត្តិរដ្ឋ ដើម្បីបម្រើផលប្រយោជន៍ទូទៅ តែត្រូវជួសជុលសំណងជូនពួកគាត់ឱ្យបានសមរម្យតាមផ្លូវច្បាប់។

### ២.១.៧ រូបវន្តបុគ្គល និងនីតិបុគ្គល

- រូបវន្តបុគ្គល គឺសំដៅទៅលើបុគ្គលដែលមានសាច់មានឈាម អាចមានជីវិតរស់នៅបាន ហើយដែលពោរពេញដោយបុគ្គលភាពគតិយុត្ត ជាបុគ្គលដែលប្រកបដោយសិទ្ធិ និងកាតព្វកិច្ច។
- នីតិបុគ្គល គឺជាបុគ្គលអរូបដែលច្បាប់និម្មិតបង្កើតមកសម្រាប់បំរើគោលដៅ និងផលប្រយោជន៍រួមរបស់បុគ្គលមួយក្រុមឬរបស់សង្គមមួយ។

## ២.២ ប្រវត្តិរដ្ឋបាលកម្ពុជា

### ២.២.១ សម័យមុនអាណានិគមបារាំង

ព្រះមហាក្សត្រចេញព្រះរាជក្រឹត្យបញ្ញត្តិតែក្នុងវិស័យរដ្ឋបាល និងក្នុងនីតិវិធីតុលាការខ្លះតែប៉ុណ្ណោះ។ ព្រះអង្គ ទ្រង់ធ្វើសាវនាការកិច្ចការរដ្ឋបាល កាលសម័យយុគកណ្តាល ( Moyen Age ) ពីរដងក្នុងមួយថ្ងៃ ។ ព្រះអង្គក៏ជាចៅក្រមផងដែរ។

### ២.២.២ សម័យអាណានិគមបារាំង

ក្នុងវិស័យរដ្ឋបាលបារាំងបានយកគំនូររចនាសម្ព័ន្ធរបស់បារាំង ដែលបានអនុវត្តនៅប្រទេសយួនយកមកចំលងដាក់ទាំងស្រុងនៅប្រទេសខ្មែរ។

### ២.២.៣ ក្រោយពីសម័យអាណានិគមបារាំង

បារាំងដកចេញទៅមែនតែអ្វីៗដែលបារាំងបានបង្កើត ហើយក្នុងវិស័យរដ្ឋបាល ទាំងរចនាសម្ព័ន្ធ ទាំងរបៀបធ្វើការក៏នៅបន្តជាប់ជានិច្ចក្នុងរបបរាស្ត្រនិយម ក៏ដូចជារបបសាធារណៈខ្មែរ លន់ នល់ដែរ។ លិខិតស្នាមផ្លូវការច្រើនសរសេរជាភាសាបារាំង របៀបធ្វើការ និងច្បាប់ទាំងឡាយនៅតែទៅតាមបារាំងទាំងអស់ពីព្រោះពួកជំនាញការ (Experts) ច្រើនតែពួកបារាំង។

## ២.៣ គោលការណ៍នៃការរៀបចំគ្រប់គ្រងរដ្ឋបាល

ពាក់ព័ន្ធក្នុងការគ្រប់គ្រងរដ្ឋបាលដែនដីនេះ គេតែងតែអនុវត្តនូវគោលការណ៍ជាសកលចំនួន២ គឺ÷

- គោលការណ៍គ្រប់គ្រងរដ្ឋបាលតាមប្រព័ន្ធមជ្ឈការ
- គោលការណ៍គ្រប់គ្រងរដ្ឋបាលតាមប្រព័ន្ធវិមជ្ឈការ

### ២.៣.១ ប្រព័ន្ធមជ្ឈការ

**ក. និយមន័យ**

ប្រព័ន្ធមជ្ឈការ គឺជាការគ្រប់គ្រងរដ្ឋមួយប្រភេទដែលរដ្ឋាភិបាលដឹកនាំរដ្ឋបាលរបស់រដ្ឋដោយផ្ទាល់ ហើយអាជ្ញាធរដែនដីគ្រាន់តែជាស្ថានប៉ុណ្ណោះ។ ប្រព័ន្ធមជ្ឈការមានគោលដៅបីចំបងដូចតទៅ ÷

- នីតិបុគ្គលសាធារណៈមានតែមួយ ( រដ្ឋ )
- អំណាចសម្រេចសេចក្តី និងបញ្ជាប្រមូលផ្តុំនៅរដ្ឋបាលកណ្តាល
- រដ្ឋបាលទាំងអស់ត្រូវរៀបចំតាមគោលការណ៍ឋានានុក្រម ដែលស្ថិតនៅក្រោមចំណុះ និងការត្រួតពិនិត្យផ្ទាល់របស់អំណាចកណ្តាលឬរដ្ឋបាលកណ្តាល។

### ២.៣.២ គុណសម្បត្តិ និងគុណវិបត្តិ

**ក. គុណសម្បត្តិ**

ចំពោះគុណសម្បត្តិមានដូចតទៅ÷

- អំណាចកណ្តាលអាចជួយខេត្តបាន។
- អំណាចកណ្តាលតែងតាំងទៅសុទ្ធតែជាមនុស្សមានសមត្ថភាព។
- មានឯកភាពជាតិបានន័យថាធ្វើឱ្យរដ្ឋសម្រេចអ្វីមួយ ដូចៗគ្នាទូទាំងប្រទេសគឺនាំឱ្យមាន ឯកភាពទាំងខាងទស្សនៈទាំងខាងអំពើរបស់រដ្ឋ។

### ខ. គុណវិបត្តិ

ចំពោះគុណវិបត្តិមានដូចជា÷

- ការធ្វើមជ្ឈការដែលប្រមូលផ្តុំរឿងទាំងអស់ យ៉ាងនេះមកថ្នាក់លើតែមួយបណ្តាល ឱ្យអង្គការនៃអំណាចកណ្តាលលិចលង់ទៅដោយសំណុំរឿងទាំងនោះ។
- ខ្វះលទ្ធិប្រជាធិបតេយ្យ (អាជ្ញាធរតែងតាំង)។
- សម្រេចកិច្ចការមិនយល់សភាពការណ៍ រដ្ឋមិនអាចដឹងពីសេចក្តីត្រូវការរបស់ប្រជារាស្ត្រនៅតាមទីកន្លែង។
- ប្រជារាស្ត្រជួបការលំបាកក្នុងជីវភាពប្រចាំថ្ងៃ ព្រោះពួកគេត្រូវឡើងមករាជធានី ដើម្បីធ្វើ កិច្ចការ ចាប់តាំងពីការងារតូចតាចឡើងទៅ។

### ២.៣.៣ បច្ចេកទេសក្នុងការរំលែកអំណាច

ដោយមានភាពតឹងរ៉ឹង ក្នុងការគ្រប់គ្រងរដ្ឋបាលកណ្តាលនៃប្រព័ន្ធមជ្ឈការបានបញ្ចេញនូវបច្ចេកទេសមួយគឺ បច្ចេកទេសក្នុងការរំលែកអំណាច ក្នុងគោលការណ៍ដើម្បីកាត់បន្ថយផលអាក្រក់របស់ខ្លួន ដែលគេហៅថា រំលែកអំណាចកណ្តាលបែង ( វិសហមជ្ឈការ )។

### ក. សញ្ញាណ និងនិយមន័យវិសហមជ្ឈការ

វិសហមជ្ឈការ គឺជាបច្ចេកទេសរដ្ឋបាលមួយ ដែលអាជ្ញាធររដ្ឋបាលកណ្តាលរំលែកកិច្ចការមួយចំនួនទៅឱ្យរដ្ឋបាលមូលដ្ឋានធ្វើការសម្រេចចិត្ត ដោយខ្លួនឯងផ្ទាល់មានន័យថាវាជាបច្ចេកទេសនៃការរៀបចំរដ្ឋបាលមួយដែលត្រូវបង្កើតឡើងដើម្បីកែសម្រួលដល់ប្រព័ន្ធមជ្ឈការ ។

ហើយដែលបានផ្តល់ទៅឱ្យអាជ្ញាធរដែនដីនូវអំណាចសម្រេចសេចក្តីលើកិច្ចការខ្លះៗ ដែលជាធម្មតាអំណាចទាំងនេះជារបស់រដ្ឋបាលកណ្តាល។

**ក.១ ចរិកលក្ខណៈ**

ក្នុងការគ្រប់គ្រងរដ្ឋបាលតាមបច្ចេកទេសនេះ គឺការគ្រប់គ្រងតាមឋានានុក្រម រដ្ឋបាលដែលអំណាចកណ្តាលបានផ្តល់ឱ្យសម្រេចតាមលំដាប់ថ្នាក់រៀងៗខ្លួន។

**ក.២ វិធីសាស្ត្រ**

ការបែងចែកអំណាចក្នុងការសម្រេចនេះគេប្រើវិធីមួយដែលហៅថា ប្រតិភូកម្ម។ ប្រតិភូកម្មនេះចែកចេញជាពីរគឺប្រតិភូកម្មអំណាចនិងប្រតិភូកម្មហត្ថលេខា។ ជួនកាលគេបញ្ជាក់ដោយពាក្យទូទៅមួយហៅថា ប្រតិភូកម្មសមត្ថកិច្ច។

**ខ. ប្រតិភូកម្មអំណាច**

គឺជាការផ្ទេរសមត្ថកិច្ចមួយបែប ទៅឱ្យអាជ្ញាធររដ្ឋបាលទាំងឡាយនៅក្នុង ឋានានុក្រមរដ្ឋបាលរបស់ខ្លួន។

**គ. ប្រតិភូកម្មហត្ថលេខា**

គឺជាវិធីមួយដែលតាមរយៈនេះ អាជ្ញាធររដ្ឋបាលនីមួយៗ អាចប្រគល់ទៅ ឱ្យសហការីណាម្នាក់របស់ខ្លួន នូវការចុះហត្ថលេខាជួសលើសេចក្តីសម្រេចខ្លះ។

**គ.១ គុណសម្បត្តិ និង គុណវិបត្តិ**

**គ.១.១ គុណសម្បត្តិ**

- ការកាត់បន្ថយការប្រើអំណាចជ្រុលហួសរបស់អាជ្ញាធរកណ្តាល
- អាជ្ញាធរមូលដ្ឋានសម្រេចបញ្ហានៅនឹងកន្លែង

- ជួយសម្រួលជីវភាព និងកិច្ចការរបស់រាស្ត្រប្រជា
- ការងារឆាប់រហ័ស ចំណេញពេលវេលា និងកាត់បន្ថយការចំណាយ

**គ.១.២ គុណវិបត្តិ**

- ខ្វះលទ្ធិប្រជាធិបតេយ្យ

**២.៣.៤ គោលការណ៍នៃការរៀបចំគ្រប់គ្រងបែបវិមជ្ឈការ**

**ក. សញ្ញាណ និង និយមន័យ**

វិមជ្ឈការមានន័យថា រាជរដ្ឋាភិបាលប្រគល់នូវភាពជាម្ចាស់លើ មុខងារ សិទ្ធិអំណាច ការទទួលខុសត្រូវ និងធនធាន ឱ្យទៅក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ដូចជាក្រុមប្រឹក្សារាជធានីក្រុង ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់មូលដ្ឋាន។

- ចរិកលក្ខណៈនៃរដ្ឋបាលវិមជ្ឈការ
- ការទទួលស្គាល់នៅប្រយោជន៍តាមមូលដ្ឋាន
- ការបោះឆ្នោតជ្រើសរើសអ្នកតំណាងដឹកនាំ
- ការផ្តល់បុគ្គលភាពគតិយុត្តដល់សមូហភាពដែនដី
- អំណាចត្រួតពិនិត្យរដ្ឋបាល

**ខ. គុណសម្បត្តិនិង គុណវិបត្តិរបស់វិមជ្ឈការ**

**ខ.១ ចំពោះគុណសម្បត្តិរបស់វិមជ្ឈការមានដូចតទៅ**

**អំពីនយោបាយ:** ជាការបន្ថយអំណាចរដ្ឋបាលកណ្តាល ហើយធ្វើឱ្យមានលក្ខណៈប្រជាធិបតេយ្យដែលអនុវត្តនៅមូលដ្ឋាន។

**អពីវិស័យរដ្ឋបាល:** បណ្តុះបណ្តាលសម្ថភាពស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យចេះទទួលខុសត្រូវ ចេះបំផុសគំនិតធ្វើផែនការអភិវឌ្ឍមូលដ្ឋានដោយគិតគូរពីប្រយោជន៍ទូទៅខ្ពស់ជាងប្រយោជន៍ផ្ទាល់ខ្លួន។

**គ. ចំពោះគុណវិបត្តិរបស់វិមជ្ឈការមានដូចតទៅ៖**

- ❑ អាចធ្វើឱ្យមានគ្រោះថ្នាក់ដល់ប្រទេសជាតិ ដោយសារតែអំណាចរដ្ឋបាលថ្នាក់ជាតិចុះថយ ហើយអំណាចរដ្ឋបាលថ្នាក់មូលដ្ឋានក្រោមជាតិកាន់តែខ្លាំង។
- ❑ ពេលខ្លះដោយសារតែសមត្ថភាពយល់ដឹងមានកម្រិត ឬការខ្វះខាតធនធានមនុស្សនៅមូលដ្ឋានខ្លះ វាធ្វើឱ្យអជ្ញាធរនៅមូលដ្ឋានរដ្ឋបាលថ្នាក់ក្រោមជាតិ មិនអាចធ្វើការងារបានល្អ មិនចេះធ្វើការងារ ឬមិនចេះធ្វើផែនការការងារ។

## តារាងប្រៀបធៀបប្រព័ន្ធវិសហមជ្ឈការ វិមជ្ឈការ

| ប្រព័ន្ធវិសហមជ្ឈការ | ប្រព័ន្ធវិមជ្ឈការ |
|---|---|
| • គ្មានបុគ្គលភាពគតិយុត្ត | • មានបុគ្គលភាពគតិយុត្ត |
| • មានអំណាចឋានានុក្រម | • គ្មានអំណាចឋានានុក្រម |
| • សមត្ថកិច្ចពាក់ព័ន្ធគ្នា | • សមត្ថកិច្ចដាច់ពីគ្នា |
| • មន្ត្រីត្រូវការតែងតាំង | • អាជ្ញាធរជ្រើសតាំង |
| • ពុំមានធនធានផ្ទាល់ទេ | • មានធនធានផ្ទាល់ |
| • គ្មានស្វ័យភាព | • មានស្វ័យភាព |
| • ការត្រួតពិនិត្យជាអទិកាល (ជាមុន) | • ការត្រួតពិនិត្យជាបច្ឆកាល (ជាក្រោយ) |

## ២.៤ គោលការណ៍អភិបាលកិច្ចល្អ

អភិបាលកិច្ចល្អ ជាវិធីសាស្ត្រ ឬមធ្យោបាយដែលរដ្ឋ ស្ថាប័ន អង្គភាព ប្រើប្រាស់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងសន្តិសុខ ដើម្បីបម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋដោយ។

បំពេញនូវគោលការណ៍ទាំង ៩ ដូចខាងក្រោមនេះ ÷

- ការចូលរួម
- នីតិរដ្ឋ
- តម្លាភាព
- ការព្រមព្រៀងឯកភាពគ្នា
- សមធម៌

- ប្រសិទ្ធិភាព និងភាពស័ក្តសិទ្ធិ
- គណនេយ្យភាព
- ការឆ្លើយតប
- ចក្ខុវិស័យជាយុទ្ធសាស្ត្រ

# ជំពូកទី ៣
# ស្ថានភាពទូទៅរបស់សាលាខណ្ឌទួលគោក



## ៣.១ ទិដ្ឋភាពទូទៅរបស់សាលាខណ្ឌទួលគោក

### ៣.១.១ ប្រវត្តិរបស់សាលាខណ្ឌ

កាលពីដើមឡើយ ខណ្ឌទួលគោកមិនទាន់មានឈ្មោះថាជាខណ្ឌទួលគោកទេ គឺមានឈ្មោះថាសង្កាត់លេខ៤ នៅសម័យសង្គមរាស្រ្តនិយម ក្រោយពីថ្ងៃរំដោះ ៧មករាឆ្នាំ១៩៧៩មក បានផ្លាស់ប្តូរពីសង្កាត់លេខ៤មកតំបន់លេខ៤ ទើបតែនៅក្នុងឆ្នាំ១៩៨៤ ត្រូវបានផ្លាស់ប្តូរឈ្មោះពីតំបន់លេខ៤ មកជា សង្កាត់លេខ៤វិញ។ ក្រោយមកនៅក្នុងឆ្នាំ១៩៨៥ សង្កាត់លេខ៤ ក៏បានរួមបញ្ចូលគ្នារវាងសង្កាត់បឹងសាឡាង សង្កាត់ទឹកល្អក់ សង្កាត់លេខ៧ ហើយបានផ្លាស់ប្តូរឈ្មោះទៅជាខណ្ឌទួលគោករហូតមកដល់ពេលបច្ចុប្បន្ននេះ។ ប្រវត្តិរបស់ថ្នាក់ដឹកនាំខណ្ឌទួលគោកឆ្លងកាត់ថ្នាក់ដឹកនាំចំនួន ៦រូបគឺ÷

លោក ជា សុផារ៉ា លោក លក គឹមសាន លោក នុត ជា លោក ឃ្លាំង ហួត លោក សេង រតនៈ រហូតមកដល់ពេលបច្ចុប្បន្ននេះគឺដឹកនាំដោយលោក ឯក យុនដឿន ជាអភិបាល នៃគណៈអភិបាលខណ្ឌទួលគោក។

### ៣.១.២ ទីតាំងភូមិសាស្រ្ត

ខណ្ឌទួលគោកជាខណ្ឌមួយក្នុងចំណោមខណ្ឌទាំង១២ នៃរាជធានីភ្នំពេញ ដែលមានព្រំប្រទល់ ខាងកើតទល់នឹងវិថីនេរុហ៍ខណ្ឌ៧មករា ខាងជើងទល់នឹងខណ្ឌឬស្សីកែវ ខាងលិចទល់ខណ្ឌឬស្សីកែវ ខណ្ឌសែនសុខ និងខណ្ឌមានជ័យ ខាងត្បូងទល់និងមហាវិថីសម្តេចព្រះមុន្នីរ៉េតខណ្ឌចំការមន។ ផ្ទៃដីសរុបរបស់ខណ្ឌទួលគោកមានទំហំ ៧,៩៩ គីឡូម៉ែតការ៉េ ស្មើនឹង១,១៧% នៃផ្ទៃដីរាជធានីភ្នំពេញ ហើយចែកចែញជា ១០សង្កាត់ និងមាន ១៤៣ភូមិ ៩៩មណ្ឌល ៥៤២ក្រុម ។

### ៣.១.៣ ស្ថានភាពរបស់ប្រជាពលរដ្ឋ

ប្រជាពលរដ្ឋដែលរស់នៅក្នុងខណ្ឌទួលគោកមានចំនួនសរុប ១៤០.៥៩២នាក់ និងស្មើ២៦.១២០គ្រួសារ ក្នុងនោះមានស្រ្តី ចំនួន ៧១.៨៦៤នាក់ ហើយចំនួនប្រជាពលរដ្ឋចាប់ពីអាយុ១៨ឆ្នាំឡើងមានចំនួន ១០៩.៦១២នាក់ ក្នុងនោះប្រុសមានចំនួន ៥៥.០២៥នាក់ ។

### ៣.១.៤ ស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ច

ប្រជាពលរដ្ឋដែលប្រកបមុខរបរសិប្បកម្មមានចំនួន ១.២២%, កសិកម្មមានចំនួន ០.០១%, ៤០%ជាអាជីវករ, បំរើសេវាកម្មមានចំនួន ២១.៧៤%, ១២.០២%ជាមន្ត្រីរាជការ, ៨.០៣%បម្រើការក្នុងវិស័យឯកជន និងអង្គការ, ២.១៩%ស៊ីឈ្នួលនិងធ្វើការសំណង, ស៊ីឈ្នួលក្នុងវិស័យកសិកម្ម សំណង់, សិប្បកម្មមានចំនួន ១,២៤០ទីតាំង, កសិកម្មមានចំនួន ៧ទីតាំង។

## ៣.២ រចនាសម្ព័ន្ធគ្រប់គ្រងរបស់សាលាខណ្ឌ

### ៣.២.១ រចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ



## ៣.២.២ ក្រុមប្រឹក្សា

ក្រុមប្រឹក្សាខណ្ឌនីមួយៗដែលបានបង្កើតឡើង ដោយការបោះឆ្នោត ស្រប តាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។

ក្រុមប្រឹក្សារាជធានីភ្នំពេញ និងក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ខណ្ឌ មាន ក្រុមប្រឹក្សាដែលត្រូវបោះឆ្នោតជ្រើសរើសជាអសកលដោយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។

- ក្រុមប្រឹក្សារាជធានីភ្នំពេញមានចំនួនសមាជិកមិនលើសពីម្ភៃមួយ ( ២១ )រូប
- ក្រុមប្រឹក្សាខេត្ត មានចំនួនសមាជិកពីប្រាំបួន (០៩) រូប ដល់ ម្ភៃមួយ (២១)រូប។
- ក្រុមប្រឹក្សាក្រុង មានចំនួនសមាជិកពីប្រាំពីរ (០៧) រូប ដល់ដប់ប្រាំរូប (១៥)រូប
- ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌមានចំនួនសមាជិកពីប្រាំពីរ (០៧)រូប ដល់ ដប់ប្រាំបួនរូប (១៩)រូប។

### ក. សិទ្ធអំណាចក្រុមប្រឹក្សា

១/ សិទ្ធអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ ២/ សិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងប្រតិបត្តិ។

### ខ. តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សា

- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ
- កសាងផែនការ
- គ្រប់គ្រងហិរញ្ញវត្ថុ
- គ្រប់គ្រងបុគ្គលិក
- រៀបចំរបាយការណ៍
- ផ្សព្វផ្សាយព័ត៌មាន
- រាយការណ៍អំពីសកម្មភាពរំលោភអំណាច
- ដោះស្រាយវិវាទ

## គ. ការប្រជុំរបស់ក្រុមប្រឹក្សា

### គ.១ ការប្រជុំសាមញ្ញ

ក្រុមប្រឹក្សាត្រូវប្រជុំសាមញ្ញ យ៉ាងហោចណាស់ដប់ពីរដង(១២)ជារៀងរាល់ឆ្នាំ។ កិច្ចប្រជុំសាមញ្ញនីមួយៗរបស់ក្រុមប្រឹក្សាត្រូវប្រារព្ធឡើងមិនឱ្យមុនម្ភៃប្រាំ (២៥) ថ្ងៃ ឬលើសពីសាមសិបប្រាំ (៣៥)ថ្ងៃ ឬបន្ទាប់ពីអង្គប្រជុំសាមញ្ញលើកមុនឡើយ។

### គ.២ ការប្រជុំវិសាមញ្ញ

ក្រុមប្រឹក្សាអាចកោះប្រជុំវិសាមញ្ញ នៅក្នុងដែនដីសមត្ថកិច្ចរបស់ខ្លួនតាមការចាំបាច់ ដើម្បីដោះស្រាយបញ្ហាបន្ទាន់ ឬករណីពិសេសណាមួយ។

### គ.៣ ប្រធានអង្គប្រជុំ

ប្រធានអង្គប្រជុំ គឺជាប្រធានអង្គប្រជុំនៅគ្រប់អង្គប្រជុំទាំងអស់របស់ក្រុមប្រឹក្សា។ ក្នុងករណីប្រធានក្រុមប្រឹក្សាអវត្តមាន ត្រូវជ្រើសរើសយកសមាជិកក្រុម

ដែលនៅក្នុងលេខរៀងលំដាប់បន្តបន្ទាប់នៃបញ្ជីបេក្ខជនជាមួយប្រធានក្រុមប្រឹក្សា និងជាអធិបតីនៃអង្គប្រជុំ។ ប្រធានអង្គប្រជុំក្រុមប្រឹក្សាមានភារកិច្ច÷

- ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សា ដោយមិនលំអៀង
- គោរព អនុវត្តច្បាប់ និងបទបញ្ជាផ្ទៃក្នុងសម្រាប់អង្គប្រជុំរបស់ក្រុមប្រឹក្សា។

### គ.៤ កូរ៉ុមនៃការប្រជុំ

រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា នឹងមានសុពលភាពទៅបានលុះត្រាតែ មានសមាជិកក្រុមប្រឹក្សាមិនតិចជាងពាក់កណ្តាល នៃសមាជិកក្រុមប្រឹក្សាទាំងមូល។

| ចំនួនសមាជិកក្រុមប្រឹក្សាសរុប | កូរ៉ុមសម្រាប់ប្រជុំ |
| --- | --- |
| • ២១រូប | • ១១រូប |
| • ១៩រូប | • ១០រូប |
| • ១៧រូប | • ០៩រូប |
| • ១៥រូប | • ០៨រូប |
| • ១៣រូប | • ០៧រូប |
| • ០៩រូប | • ០៥រូប |
| • ០៧រូប | • ០៤រូប |

**គ.៥ កំណត់ហេតុនៃអង្គប្រជុំ**

កំណត់ហេតុនៃអង្គប្រជុំរបស់ក្រុមប្រឹក្សាត្រូវកំណត់នូវបញ្ហាដូចខាងក្រោម÷

- ទីកន្លែង និងកាលបរិច្ឆេទ
- មានកូរ៉ុមគ្រប់ចំនួន
- បញ្ជីឈ្មោះ និងអង្គភាពរបស់អ្នកចូលរួមក្នុងប្រជុំ

- សេចក្តីសម្រេច និងលទ្ធផលនៃការបោះឆ្នោតអនុម័តលើបញ្ហាផ្សេងៗក្នុងរបៀបវារៈ នៃកិច្ចប្រជុំរួមទាំងបញ្ហាបានបន្ថែមនៅក្នុងរបៀបវារៈ។
- របៀបវារៈពេលវេលា និងទីកន្លែងសម្រាប់កិច្ចប្រជុំលើកក្រោយ
- បញ្ហាផ្សេងៗទៀតដែលត្រូវកត់ត្រា
- ពេលវេលាបិទអង្គប្រជុំ

**គ៦. អំពីការខកខានមិនបានចូលរួមប្រជុំ**

**ឃ. អំពីវិន័យ និងទណ្ឌកម្មខាងពិន័យ**

**ឃ.១ ទណ្ឌកម្មខាងវិន័យ**

ចំពោះសមាជិកក្រុមប្រឹក្សាខណ្ឌមានដូចជា

- ទណ្ឌកម្មខាងវិន័យចំពោះសមាជិកក្រុមប្រឹក្សាខណ្ឌ ដែលខកខានមកប្រជុំដោយគ្មានច្បាប់អនុញ្ញាត។
- ទណ្ឌកម្មខាងវិន័យចំពោះសមាជិកក្រុមប្រឹក្សានៅក្នុងកិច្ចប្រជុំ។

## ឃ.២ ទណ្ឌកម្មខាងពិន័យ

- ទទួលការក្រើនរំលឹកពីប្រធានក្រុមប្រឹក្សាខណ្ឌ (០១លើក)
- គ្មានច្បាប់អនុញ្ញាតចំនួនពីរ ០២លើកមិនជាប់គ្នា ក្នុងអំឡុងពេល១២ខែ ត្រូវទទួលការក្រើនរំលឹកដោយចុះក្នុងកំណត់ហេតុ និងត្រូវកាត់ប្រាក់បំណាច់ចំនួនម្ភៃប្រាំ (២៥) ភាគរយ។
- គ្មានច្បាប់អនុញ្ញាតចំនួនបី ០៣លើកមិនជាប់គ្នា ក្នុងអំឡុងពេល១២ខែ ត្រូវទទួលការស្តីបន្ទោសជាលាយលក្ខណ៍អក្សរ និងត្រូវកាត់ប្រាក់បំណាច់ចំនួនហាសិប (៥០ ) ភាគរយ។

## ង. សមាសភាព

សមាសភាពរបស់ក្រុមប្រឹក្សាខណ្ឌទួលគោក នៃរាជធានីភ្នំពេញ នីតិកាលទី២ មានចំនួន ១៩រូប ក្នុងនោះមានស្ត្រី ចំនួន ៤រូប។ ប្រធានក្រុមប្រឹក្សាខណ្ឌទួលគោក លោក ម៉ែន សេរី។

### ៣.២.៣ គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា

យោងមាត្រា ១១៤ នៃច្បាប់ស្តីការគ្រប់គ្រងរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌឆ្នាំ ២០០៨ គ្រប់ក្រុមប្រឹក្សាមានកាតព្វកិច្ចបង្កើតគណៈកម្មាធិការយ៉ាងតិចចំនួន៣គណៈកម្មាធិការ រួបមាន÷

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
- គណៈកម្មាធិការលទ្ធកម្ម

ក្នុងខណ្ឌទួលគោកក្រុមប្រឹក្សាខណ្ឌបានបង្កើតគណៈកម្មាធិការមួយទៀតគឺ គណៈកម្មាធិការរៀបចំដែនដីនគរូបនីយកម្មមួយបន្ថែមទៀត។

**ក. គណៈកម្មាធិការរៀបចំដែនដី នគរូបនីយកម្ម**

លោក ឯក យុនដឿន អភិបាលនៃគណៈអភិបាលខណ្ឌទួលគោក ជាប្រធានគណៈកម្មាធិការ និងលោក ធឹម សំណាន ជាអនុប្រធាន និងមានសមាជិកចំនួន ៣៨នាក់។

**ក.២ តួនាទី និងភារកិច្ច**

គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មមានតួនាទី និងភារកិច្ចដូចខាងក្រោម÷

- ផ្តួចផ្តើម និងរៀបចំប្លង់គោលប្រើប្រាស់ដីថ្នាក់ខណ្ឌ
- តាមដាន ត្រួតពិនិត្យ និងជំរុញអនុវត្តប្លង់គោលប្រើប្រាស់ដីថ្នាក់ខណ្ឌ និងផែនការប្រើប្រាស់ដីថ្នាក់សង្កាត់ឱ្យមានប្រសិទ្ធភាព និងចំទិសដៅ។

- ដឹកនាំ ពិគ្រោះយោបល់ សម្របសម្រួល ជាមួយការិយាល័យ និងអង្គភាពពាក់ព័ន្ធក្នុងការរៀបចំប្លង់គោលប្រើប្រាស់ដីថ្នាក់ខណ្ឌ។
- កែសម្រួល និងធ្វើបច្ចុប្បន្នកម្មលើប្លង់គោលប្រើប្រាស់ដីថ្នាក់ខណ្ឌ និងប្រើប្រាស់ដីថ្នាក់សង្កាត់។
- ធ្វើរបាយការណ៍ ប្រចាំឆមាស និងប្រចាំឆ្នាំជូនគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់រាជធានីភ្នំពេញ ។
- លើកផែនការសកម្មភាព និងគម្រោងថវិកាប្រចាំឆ្នាំសម្រាប់រៀបចំប្លង់គោលប្រើប្រាស់ដីថ្នាក់ខណ្ឌ។
- បំពេញភារកិច្ចផ្សេងៗ ដែលពាក់ព័ន្ធនិងការរៀបចំកសាងប្លង់គោល។
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលគណៈកម្មាធិការរៀបចំដែនដី និងនគររូបនីយកម្មរាជធានីភ្នំពេញប្រគល់ជូន។

**ខ. គណៈកម្មាធិការលទ្ធកម្ម**

លោក ឯក ឃុនដឿន អភិបាលនៃគណៈអភិបាលខណ្ឌទួលគោក ជាប្រធានគណៈកម្មាធិការ និងលោក លោក ប៉ាង លីដា និងមានសមាជិកចំនួន ៦នាក់។

**ខ.២ តួនាទី និងភារកិច្ច**

- គណៈកម្មាធិការលទ្ធកម្ម របស់រដ្ឋបាលខណ្ឌទួលគោក មានភារកិច្ចដូចខាងក្រោម÷
- គោរពខ្ជាប់ខ្ជួនតាមក្រមសីលធមិលទ្ធកម្ម
- ពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំ ដែលរៀបចំដោយអង្គភាពលទ្ធកម្ម ដើម្បីដាក់ជូនក្រុមប្រឹក្សា ពិនិត្យ និងឯកភាព មុននឹងផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីពិនិត្យ និងអនុម័ត។
- ណែនាំឱ្យអង្គភាពលទ្ធកម្ម អនុវត្តឱ្យបានត្រឹមត្រូវតាមផែនការលទ្ធកម្ម។

- ប្រជុំវាយតម្លៃ កំណត់បុរេលក្ខណៈសម្បត្តិចំពោះកិច្ចការលទ្ធកម្ម ដែលមានលក្ខណៈស្មុគស្មាញ។
- ត្រួតពិនិត្យ និងផ្តល់ទិដ្ឋការលើឯកសារដេញថ្លៃ ដែលស្ថិតក្នុងសិទ្ធិសម្រេចរបស់ខ្លួន។
- ប្រជុំបើកសំណើ ដេញថ្លៃ ពិគ្រោះថ្លៃ ស្ទង់តម្លៃ ឬចរចាថ្លៃ។
- ប្រជុំវាយតម្លៃ ប្រគល់កិច្ចសន្យា
- ត្រួតពិនិត្យ និងវាយតម្លៃឡើងវិញ លក្ខណៈសម្បត្តិរបស់អ្នកដេញថ្លៃនាំមុខមុនការសម្រេចប្រគល់កិច្ចសន្យា។
- ជូនដំណឹង ស្តីពីការសម្រេចប្រគល់កិច្ចសន្យាទៅឱ្យអ្នកដេញថ្លៃឈ្នះ និងចម្លងជូនទៅគ្រប់អ្នកដេញថ្លៃចាញ់។

- ផ្សព្វផ្សាយលទ្ធផល នៃការដេញថ្លៃជាសាធារណៈ
- រាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួន អំពីដំណើរការកិច្ចលទ្ធកម្មក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញតាមការចាំបាច់ និងការកំណត់របស់ក្រុមប្រឹក្សា។
- ផ្ញើរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបន្ទាប់ពីរបាយការណ៍នោះត្រូវបានអនុម័តដោយក្រុមប្រឹក្សារបស់ខ្លួន។
- ដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្មតាមសមត្ថកិច្ចរបស់ខ្លួន។
- ត្រួតពិនិត្យឡើងវិញ លើទំហំទឹកប្រាក់ នៃកញ្ចប់លទ្ធកម្មនីមួយៗ មុននិងចាប់ផ្តើមដំណើរការលទ្ធកម្ម។

**គ. គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ**

លោក លោកស្រី ញ៉ែម មុំ សមាជិកនៃក្រុមប្រឹក្សាខណ្ឌ ជាប្រធានគណៈកម្មាធិការ និង លោកស្រី ហួត សុខរី លោកស្រី សុត ចណ្ណារ៉ានិងមានសមាជិកចំនួន ៣៤នាក់។

**គ.២ តួនាទី និងភារកិច្ច**

តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារគឺផ្តល់យោបល់ដល់ក្រុមប្រឹក្សាខណ្ឌ និងគណៈអភិបាលខណ្ឌលើកិច្ចការសំខាន់ៗដូចជា÷

- ជម្រុញឱ្យមានការប្រមូលព័ត៌មានរបស់សហគមន៍
- ប្រមូល និងវិភាគព័ត៌មាន និងទិន្នន័យដែលទាក់ទងនឹងយេនឌ័រ និងតម្រូវការស្ត្រី យុវវ័យ។

- ចូលរួមក្នុងការរៀបចំតាក់តែង ត្រួតពិនិត្យ និងវាយតម្លៃក្នុងការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា ទាក់ទងនឹងការលើកកម្ពស់ និងឆ្លើយតបលើបញ្ហាសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ។
- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ខ្លួន ដើម្បីដាក់បញ្ចូលទៅក្នុងផែនការសកម្មភាព និងថវិការបស់ក្រុមប្រឹក្សា។
- ស្វែងរកការគាំទ្រពីក្រុមប្រឹក្សា និងគណៈអភិបាល និងគណៈកម្មាធិការផ្សេងទៀតនៃក្រុមប្រឹក្សា ដើម្បីលើកផែនការសកម្មភាពសម្រាប់ដោះស្រាយបញ្ហាពាក់ព័ន្ធសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។
- ជម្រុញការលើកកម្ពស់ការយល់ដឹងអំពីច្បាប់ និងគោលនយោបាយនានាទាក់ទងនឹងសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ។

- សហការ និងផ្តល់ការគាំទ្រដល់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សាប្រភេទផ្សេងទៀត
- លើកសំណើ និងផ្តល់យោបល់ជូនក្រុមប្រឹក្សា ឬគណៈអភិបាល អំពីវិធានការសមស្របនានា ដើម្បីជម្រុញឱ្យមានការចូលរួមពីសមត្ថកិច្ចពាក់ព័ន្ធ ។
- ចូលរួមក្នុងការកសាងចក្ខុវិស័យ ជាយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍនៅក្នុងដែនដីសមត្ថកិច្ចរបស់ក្រុមប្រឹក្សា និងដើម្បីឱ្យសម្រេចបាននូវសមភាពយេនដ័រ និងការផ្តល់សេវាផ្សេងៗដែលពាក់ព័ន្ធនឹងសមភាពយេនឌ័រស្ត្រី យុវវ័យ និងកុមារ។
- ពិនិត្យមើលការអនុវត្តគោលនយោបាយសមភាពយេនឌ័រ និងស្ថានភាពស្ត្រី យុវវ័យ និងកុមារ ។
- ស្វែងរកការគាំទ្រ ដើម្បីជំរុញឱ្យមានការធ្វើសេចក្តីសម្រេចពាក់ព័ន្ធនឹងការងារអភិវឌ្ឍនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។

- រាយការណ៍ជូនក្រុមប្រឹក្សា លើបញ្ហាដែលទាក់ទងនឹងសមភាពយេនឌ័រ ការបង្កើនសមត្ថភាពស្ត្រី និងបញ្ហាយុវវ័យ និងកុមារ។
- គាំទ្រគ្រប់កិច្ចខំប្រឹងប្រែង ដើម្បីកៀរគរមូលនិធិសម្រាប់កាងារសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ភារកិច្ចរបស់ក្រុមប្រឹក្សា។

**ឃ. គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស**

លោក ឯក យុនដឿន អភិបាលនៃគណៈអភិបាលខណ្ឌជាំប្រធាន និងលោក ប៉ាង លីដា ជាអនុប្រធានគណៈកម្មាធិការ និងមានសមាជិកចំនួន៤២នាក់។

- សម្របសម្រួលកិច្ចការរបស់ក្រុមប្រឹក្សាខណ្ឌ ជាមួយការិយាល័យអង្គភាពរបស់ក្រសួង ស្ថាប័ននានា

- ផែនការអភិវឌ្ឍ និងថវិកា
- កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលនៅក្នុងរដ្ឋបាលឯកភាពខណ្ឌ
- កិច្ចសហប្រិត្តបត្តិការ និងការសម្របសម្រួលរវាងក្រុមប្រឹក្សាខណ្ឌជាមួយក្រុមប្រឹក្សាសង្កាត់នៅក្នុងខណ្ឌ
- មុខងារ និងធនធាន

**៣.២.៤ គណៈអភិបាល**

គណៈអភិបាល បង្កើតឡើងសម្រាប់ដឹកនាំការងារទូទៅនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ គណៈអភិបាល ជាការប្រមូលផ្តុំអភិបាល និងអភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

គណៈអភិបាលកើតឡើងដោយការតែងតាំងពីនាយករដ្ឋមន្ត្រី ឬរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ គណៈអភិបាលមិនមែនជាសមាជិកក្រុមប្រឹក្សាឡើយ ។

គណៈអភិបាល ជាសេនាធិការជាអ្នកទទួលអនុវត្តរាល់សេចក្ដីសម្រេច និងផ្ដល់យោបល់ឱ្យក្រុមប្រឹក្សាដើម្បីឱ្យក្រុមប្រឹក្សាសម្រេចនូវការអនុវត្តតាមមុខងារ សិទ្ធិអំណាច និងភារកិច្ចរបស់ខ្លួន។ អាណត្តិរបស់អភិបាល អភិបាលរងគឺមិនលើសពី ៤ឆ្នាំ។

**ក. លក្ខណសម្បត្តិនៃការតែងតាំង**

១/ លក្ខខណ្ឌនៃការតែងតាំងអភិបាលក្រុង ស្រុក ខណ្ឌ គឺជ្រើសរើសមន្ត្រីក្របខណ្ឌរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ដែលមានលក្ខណសម្បត្តិដូចខាងក្រោម÷

- មានឋានន្តរស័ក្តិអនុមន្ត្រីឡើង
- មានអាយុយ៉ាងតិច ៣០ឆ្នាំ គិតត្រឹមថ្ងៃតែងតាំង
- មានបទពិសោធន៍ការងាររដ្ឋបាលសាធារណៈយ៉ាងតិច ៥ឆ្នាំ
- មានសញ្ញាប័ត្របរិញ្ញាបត្រ

- មានឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងរយៈពេលនៃការតែងតាំង
- មិនធ្លាប់មានទោសបទឧក្រិដ្ឋ ឬមជ្ឈឹម

២/ លក្ខខណ្ឌនៃការតែងតាំងអភិបាលរងក្រុង ស្រុក ខណ្ឌ គឺជ្រើសរើសមន្ត្រីក្របខណ្ឌក្រសួងមហាផ្ទៃដែលមានលក្ខណសម្បត្តិដូចខាងក្រោម÷

- មានឋានន្តរស័ក្តិនាយក្រមការឡើង
- មានអាយុយ៉ាងតិច ២៥ឆ្នាំ គិតត្រឹមថ្ងៃតែងតាំង
- មានបទពិសោធន៍ការងាររដ្ឋបាលសាធារណៈយ៉ាងតិច ៣ ឆ្នាំ
- មានសញ្ញាប័ត្របរិញ្ញាបត្ររង
- មានឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងរយៈពេលនៃការតែងតាំង
- មិនធ្លាប់មានទោសបទឧក្រិដ្ឋ ឬមជ្ឈឹម

អភិបាល អភិបាលរង អាចបញ្ឈប់ពីមុខតំណែងគណៈអភិបាលមុនអាណត្តិក្នុងលក្ខខណ្ឌដូចខាងក្រោម

- បាត់បង់លក្ខណសម្បត្តិជាអភិបាល ឬអភិបាលរង
- អសមត្ថភាព
- បំពេញការងារមិនបានល្អ
- មានបញ្ហាសុខភាព ឬបាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច។
- បោះបង់ចោលការងារ
- ប្រព្រឹត្តខុសក្រមសីលធម៌វិជ្ជាជីវៈ

**ខ. សមាសភាព និងតួនាទីភារកិច្ចរបស់គណៈអភិបាលខណ្ឌទួលគោក**

**សមាសភាពរបស់គណៈអភិបាលខណ្ឌទួលគោកមាន÷**

លោក **ឯក យុនធឿន** ជាអភិបាលខណ្ឌ នៃគណៈភិបាលខណ្ឌ

លោក **សាំង សុភៈវិចិត្រ** ជាអភិបាលរងខណ្ឌ

លោក **ធីម សំអាន** អភិបាលរងខណ្ឌ

លោក **សុត ចណ្ណារ៉ា** អភិបាលរងខណ្ឌ

លោក **ប៉ាង លីផា** អភិបាលរងខណ្ឌ

## ខ.២ តួនាទីរបស់គណៈអភិបាលខណ្ឌ

គណៈអភិបាលខណ្ឌ មានតួនាទី និងភារកិច្ចដូចជា ÷

- គណៈអភិបាលខណ្ឌ ត្រូវធ្វើការសិក្សាស្រាវជ្រាវ ដើម្បីផ្តល់យោបល់ជូនក្រុមប្រឹក្សាខណ្ឌអំពីកិច្ចការនានាដែលពាក់ព័ន្ធនឹងអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិរបស់ក្រុមប្រឹក្សាខណ្ឌ ។
- គណៈអភិបាលខណ្ឌមានតួនាទីជាតំណាងក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាលក្នុងខណ្ឌ។
- ការរៀបចំយុទ្ធសាស្ត្រ និងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន សម្រេបតាមច្បាប់ស្តីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។
- ការបង្កើត ការសម្រួល ឬការរំសាយការិយាល័យនានា

- ធ្វើជាប្រធានគណៈបញ្ជាការឯកភាពខណ្ឌ
- រៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មានដល់សាធារណៈជន
- ការបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានា
- របាយការណ៍ប្រចាំខែ ត្រីមាស និងឆមាស
- កំណត់នីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុសម្រាប់ការិយាល័យ និងបុគ្គលិករបស់ក្រុមប្រឹក្សាខណ្ឌ
- ការបង្កើត ការសម្រួល ឬការរំសាយការិយាល័យនានា
- ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងការធ្វើបច្ចុប្បន្នភាព
- ការងារហិរញ្ញវត្ថុ ថវិកា និងទ្រព្យសម្បត្តិរបស់ខណ្ឌ

### ៣.២.៥ នាយករដ្ឋបាល

#### ក. លក្ខណសម្បត្តិនៃការតែងតាំង

នាយករដ្ឋបាលសាលាខណ្ឌដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសំណើរបស់អភិបាលខណ្ឌ ដោយយោងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាខណ្ឌ។

នាយករដ្ឋបាលសាលាខណ្ឌ ត្រូវបានតែងតាំងឡើងពីក្នុងចំណោមមន្ត្រីដែលស្ថិតក្នុងឋានន្តរស័ក្តិចាប់ពី ក្រមការដើមខ្សែនៃក្របខណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ។

នាយករដ្ឋបាលសាលាខណ្ឌ ត្រូវមាននាយករងរដ្ឋបាលសាលាខណ្ឌយ៉ាងច្រើនពីរ (០២)រូបជាជំនួយការតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសំណើរបស់អភិបាលខណ្ឌ ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាខណ្ឌ។

#### ខ. តួនាទី និងភារកិច្ចរបស់នាយករដ្ឋបាល

នាយករដ្ឋបាលសាលាខណ្ឌមានភារកិច្ច

- រៀបចំ និងដាក់ជូនគណៈអភិបាលខណ្ឌ ពិនិត្យ សម្រេចនូវកិច្ចការរដ្ឋបាលប្រចាំថ្ងៃ
- រៀបចំ និងដាក់ជូនគណៈអភិបាលខណ្ឌនូវវិធាន និងគោលការណ៍ក្នុងការអនុវត្តដីកានូវសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាខណ្ឌ។
- ធ្វើជាសេនាធិការជូនអភិបាលខណ្ឌ និងប្រធានក្រុមប្រឹក្សាខណ្ឌ
- ត្រៀមរៀបចំកិច្ចការនានាសម្រាប់បម្រើឱ្យកិច្ចការប្រជុំទាំងអស់
- គ្រប់គ្រងនិងប្រើប្រាស់ត្រារដ្ឋបាលខណ្ឌឱ្យបានត្រឹមត្រូវតាមការកំណត់។
- ធានារក្សាទុកឱ្យបានត្រឹមត្រូវនឹងគង់វង្សនូវឯកសារ លិខិតបទដ្ឋានទាំងអស់របស់ក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ និងរដ្ឋបាលខណ្ឌរបស់ខ្លួន។

| ក្រុមប្រឹក្សា | គណៈអភិបាល |
| --- | --- |
| បោះឆ្នោតដោយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ | តែងតាំងដោយរាជរដ្ឋាភិបាល |
| មានអាណត្តិ ៥ឆ្នាំ | មានអាណត្តិ ៥ឆ្នាំ |
| ធ្វើសេចក្ដីសម្រេចសម្រាប់ដែនដីរបស់ខ្លួន | អនុវត្តតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា |
| មានគណេយ្យភាពដោយផ្ទាល់ ចំពោះប្រជាពលរដ្ឋ និងដោះស្រាយដោយប្រយោលចំពោះរាជរដ្ឋាភិបាល | មានគណនេយ្យភាពចំពោះក្រុមប្រឹក្សា និងរដ្ឋ |
| ពិនិត្យមើលការងារគណៈអភិបាល | រាយការណ៍ជូនក្រុមប្រឹក្សាជាប្រចាំ |
| អនុម័តផែនការ និងថវិកាអភិវឌ្ឍន៍ | រៀបចំផែនការ និងថវិការអភិវឌ្ឍន៍ដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យ |
| ប្រភព: ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ១៤. ៣៤. ៣១. ១៥ | |

### ៣.២.៦ ការិយាល័យចំណុះរដ្ឋបាលសាលាខណ្ឌទួលគោក

១/ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ ២/ការិយាល័យផែនការ និងអភិវឌ្ឍ ៣/ការិយាល័យអន្តរវិស័យ ៤/ការិយាល័យច្រកចេញចូលតែមួយ ៥/អង្គភាពលទ្ធកម្ម។

### ៣.២.៧ សមាសភាពក្រុមប្រឹក្សាសង្កាត់

នៅក្នុងខណ្ឌទួលគោកមានសង្កាត់ចំនួន ១០ សង្កាត់ ១៤៣ភូមិ និងក្រុមចំនួន ៥៤២ ក្រុម។ ចំពោះចំនួនសមាសភាពរបស់ក្រុមប្រឹក្សាសង្កាត់នីមួយៗ គឺអាស្រ័យទៅតាមចំនួនប្រជាសាស្ត្ររបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងសង្កាត់នីមួយៗនោះ ហើយចំនួនសមាសភាពរបស់ក្រុមប្រឹក្សាសង្កាត់គឺចាប់ពី ៥រូបឡើងទៅដល់ ១១រូប។

## ៣.៣ ការគ្រប់គ្រងរដ្ឋបាលខណ្ឌទួលគោក

### ៣.៣.១ ការងាររដ្ឋបាល

- ការងារលិខិតស្នាម និងឯកសារប្រជាពលរដ្ឋ
- ការងារគ្រប់គ្រងប្រជាពលរដ្ឋ
- ការងារអត្រានុកូលដ្ឋាន
- ការផ្សព្វផ្សាយព័ត៌មាន និងទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ
- ការងារគណៈអភិបាល
- ការងារក្រុមប្រឹក្សា និងគណៈកម្មាធិការនានា

### ៣.៣.២ ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគខណ្ឌ

- គម្រោងវិនិយោគបីឆ្នាំរំកិលខណ្ឌ
- ការអនុវត្តគម្រោងវិនិយោគខណ្ឌ
- ការអនុវត្តផែនការសកម្មភាព និងថវិកា ផអ៣

### ៣.៣.៣ ការគ្រប់គ្រងធនធានមនុស្ស

- ស្ថិតិក្រុមប្រឹក្សាខណ្ឌ និងបុគ្គលិក
- ស្ថិតិក្រុមប្រឹក្សាសង្កាត់ និងបុគ្គលិក

### ៣.៣.៤ ការងារអន្តរវិស័យ

- ការដោះស្រាយ និងសម្រុះសម្រួលទំនាស់
- កិច្ចការច្រកចេញចូលតែមួយ
- កិច្ចការសេវាសង្គម និងការបង្កើនសិទ្ធិអំណាចស្ត្រី

### ៣.៤ សេវាសាធារណៈដែលផ្ដល់ដោយសាលាខណ្ឌទួលគោក

- ការងារនីត្យានុកូលកម្ម (បញ្ជាក់លើឯកសារថតចម្លង)
- ការងារអត្រានុកូលដ្ឋាន
- ការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យ ដែលពុំទាន់ចុះបញ្ជី
- វិស័យវប្បធម៌ និងវិចិត្រសិល្បៈ
- វិស័យអប់រំ យុវជននិងកីឡា
- វិស័យទេសចរណ៍

### ៣.៥ សមិទ្ធផលដែលខណ្ឌសម្រេចបាន

សមិទ្ធផលដែលខណ្ឌសម្រេចបានមានជាច្រើន ក្នុងនោះរួមមានដូចជា វិស័យការងារឧស្សាហកម្ម និងសិប្បកម្ម ការងារវិស័យទេសចរណ៍ ការងារសាធារណៈ និងដឹកជញ្ជូនការងារគយ និងរដ្ឋាករការងារពាណិជ្ជកម្មសង្គមកិច្ចការគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយជាដើម។ល។

# ជំពូកទី ៤

# ការវិភាគទិន្នន័យ និងរបកគំហើញ

## ៤.១ ការវិភាគរបកទិន្នន័យ

ដោយយោងតាមការចុះកម្មសិក្សាដោយផ្ទាល់ នៅសាលាខណ្ឌទួលគោក និងចុះសម្ភាសន៍ជាមួយប្រជាពលរដ្ឋដែលរស់នៅក្នុងខណ្ឌទួលគោក ជាលទ្ធផលនៃការសិក្សាស្រាវជ្រាវកន្លងមកបានបង្ហាញឱ្យឃើញដូចតទៅ÷

### ៤.១.១ ការវិភាគទៅលើធនធានមនុស្ស

ធនធានមនុស្សសម្រាប់បម្រើការងារឱ្យសាលាខណ្ឌ នៅមានកម្រិតនៅឡើយ នៅក្នុងនោះសាលាខណ្ឌនៅខ្វះមន្ត្រីជំនាញផ្នែក ព័ត៌មានវិទ្យា ផ្នែកការងារអន្តរវិស័យ និងផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ។

### ៤.១.២ ការវិភាគទៅលើការអនុវត្តការងាររបស់មន្ត្រីសាលាខណ្ឌ

ការអនុវត្តការងាររបស់ក្រុមប្រឹក្សាខណ្ឌ គណៈអភិបាល មន្ត្រីក្របខណ្ឌ ក៏ដូចជាមន្ត្រីជាប់កិច្ចសន្យានៅក្នុងខណ្ឌទួលគោក

គឺមានទំនួលខុសត្រូវខុសទៅលើកិច្ចការងាររបស់ខ្លួន ទៅតាមផ្នែកនីមួយៗ និងទៅតាមតួនាទីដែលច្បាប់បានកំណត់។ កត្តានេះហើយដែលជាមូលហេតុធ្វើឱ្យខណ្ឌទទួលបានសមិទ្ធផលជាច្រើនគួរឱ្យកត់សម្គាល់។

### ៤.១.៣ ការវិភាគទៅលើការផ្តល់សេវាផ្នែករដ្ឋបាល

ប្រជាពលរដ្ឋសឹងតែ ១០០ ភាគរយដែលបានទទួលសេវាផ្នែករដ្ឋបាលដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខណ្ឌ។ តាមលទ្ធផលនៃការស្រាវជ្រាវបានបង្ហាញឱ្យឃើញថា ខណ្ឌបានបំពេញតួនាទី ភារកិច្ចលើផ្នែកលិខិតស្នាមបានយ៉ាងច្រើន នៅក្នុងមូលដ្ឋានដូចជាកិច្ចការអត្រានុកូលដ្ឋានមាន ការធ្វើសំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ សំបុត្រមរណភាព លិខិតបញ្ជាក់ទីលំនៅ ចុះបញ្ជីឈ្មោះអ្នកបោះឆ្នោត និងបញ្ជាក់លិខិតមួយចំនួនដូចជា លិខិតបញ្ជាក់ការងារ លិខិតសម្គាល់យានយន្ត និងលិខិតបញ្ជាក់ការសិក្សាជាដើម។ ល។

**៤.១.៤ ការវិភាគលើស្ថានភាពភូមិសាស្ត្រ**

ខណ្ឌទួលគោក គឺជាខណ្ឌមួយដែលមានផ្ទៃដីធំនៅក្នុងចំណោមខណ្ឌទាំង ១២ នៃរាជធានីភ្នំពេញ ហើយខណ្ឌនេះស្ថិតនៅក្រុងដែលជាទីប្រជុំជនមានមនុស្សកោះកររស់នៅ ដែលអំណាយផលទៅលើវិស័យមួយចំនួនដូចជា វិស័យពាណិជ្ជកម្ម ឧស្សាហកម្ម ទេសចរណ៍ និងវិស័យអប់រំផងដែរ។

**៤.១.៥ ការវិភាគទៅលើធនធានថវិការបស់ខណ្ឌ**

យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៤៤ ចែងថា រាជធានី ខេត្ត ក្រុង ស្រុក ត្រូវមានថវិកាផ្ទាល់ខ្លួន ដែលហៅកាត់ថា ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ។

ការគ្រប់គ្រង និងការអនុវត្តគម្រោងថវិកាប្រចាំឆ្នាំ ត្រូវផ្អែកតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរៀបចំឡើងស្របតាមច្បាប់នេះ និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

**៤.១.៦ ការវិភាគទីលើផ្នែកធនធានបរិស្ថាន**

យោងតាមការសម្ភាសជាមួយមន្ត្រីរបស់សាលាខណ្ឌបានឱ្យដឹងថា ខណ្ឌទួលគោកជាខណ្ឌមួយដែលស្ថិតនៅចំកណ្តាលរាជធានីភ្នំពេញ ហើយជាខណ្ឌមួយដែលមានផ្ទៃដីធំក្នុងចំណោមខណ្ឌធំនៅក្នុងរាជធានីភ្នំពេញ ថែមទាំងជាតំបន់ដែលប្រមូលផ្តុំដោយសហគ្រាសធំៗ អាគារពាណិជ្ជកម្ម ផ្សារទំនើប ភោជនីយដ្ឋាន សាកលវិទ្យាល័យរដ្ឋ និងឯកជន ស្ថានអាកាស ហើយនិងសំបូរទៅដោយហេដ្ឋារចនាសម្ព័ន្ធជាច្រើនទៀតផងដែរ។ ដែលយើងអាចកត់សម្គាល់បានថា ជាខណ្ឌដែលមានសក្តានុភាពខ្លាំងក្នុងចំណោមខណ្ឌទាំង ១២របស់រាជធានីភ្នំពេញ។

## ៤.២ របកគំហើញ

### ៤.២.១ ចំណុចខ្លាំង

ជាលទ្ធផលនៃការសិក្សាស្រាវជ្រាវ បានបង្ហាញឱ្យឃើញពីចំណុចខ្លាំងរបស់សាលាខណ្ឌដែលបានកត់សម្គាល់ដូចខាងក្រោម÷

- ក្រុមប្រឹក្សាខណ្ឌ និងគណៈអភិបាលខណ្ឌប្រជុំជាទៀងរាល់ខែ ដែលធ្វើឱ្យសម្រេចបាននូវសមិទ្ធផលបានជាច្រើន។
- ក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ និងមន្ត្រីសាលាខណ្ឌមានឆន្ទៈខ្ពស់ទទួលក្នុងការខុសត្រូវក្នុងការងាររបស់ខ្លួន។
- វិវាទ និងបញ្ហាដែលបានកើតឡើងក្នុងខណ្ឌ ត្រូវបានមន្ត្រីសាលាខណ្ឌធ្វើការដោះស្រាយបានយ៉ាងឆាប់រហ័ស និងប្រកបដោយប្រសិទ្ធភាពខ្ពស់។
- មន្ត្រីសាលាខណ្ឌធ្វើការចុះដោះស្រាយវិវាទផ្សេងៗ ជូនដល់ប្រជាពលរដ្ឋនៅមូលដ្ឋានដោយផ្ទាល់។

- រាល់ការកសាងសមិទ្ធផល និងការជួសជុលនៅក្នុងទួលគោកគឺសុទ្ធតែមានគម្រោងប្រចាំឆ្នាំរបស់សាលាខណ្ឌយ៉ាងច្បាស់លាស់។
- ប្រជាពលរដ្ឋមានការទទួលយកនូវសេវាកម្មរបស់សាលាខណ្ឌដែលផ្ដល់ឱ្យ
- តាមសង្កាត់នីមួយៗ តែងតែចែករំលែកពត៌មានថ្មីៗជូនទៅដល់ប្រជាពលរដ្ឋមកចូលរួមក្នុងការផ្ដល់ព័ត៌មានផ្សេងៗ។
- មានការដាក់កងកម្លាំងចុះល្បាតជាប្រចាំដើម្បីរក្សាសណ្ដាប់ធ្នាប់ជូនប្រជាពលរដ្ឋ
- នៅក្នុងខណ្ឌទាំងមូលមានការប្រើទឹកស្អាត និងមានហេដ្ឋារចនាសម្ព័ន្ធល្អគ្រប់គ្រាន់។
- ជីវភាពរបស់ប្រជាពលរដ្ឋនៅក្នុងខណ្ឌទួលគោកមានភាពធូរធា

- ប្រជាពលរដ្ឋទាំងមូលមានការយល់ច្រើនពីបញ្ហាសង្គម
- ខណ្ឌមានការចុះបង្ក្រាប់កន្លែងល្បែងស៊ីសង និងកន្លែងលេងហ្គេមដែលគ្មានអាជ្ញាប័ណ្ណត្រឹមត្រូវពីសាលាខណ្ឌ។

**៤.២.២ ចំណុចខ្សោយ**

ក្រោយពីបានចុះធ្វើការសិក្សាស្រាវជ្រាវ បានបង្ហាញឱ្យឃើញពីចំណុចខ្សោយរបស់ខណ្ឌដូចមានដូចខាងក្រោម÷

- នៅមានខ្វះមន្រ្តីក្របខណ្ឌ សម្រាប់បម្រើការងារនៅតាមការិយាល័យមួយចំនួនដែលស្ថិតក្រោមចំណុះរបស់ខណ្ឌទួលគោក។
- នគរបាលមួយចំនួនតូច ខ្វះការសហការទ៍ជាមួយប្រជាពលរដ្ឋនៅពេលមានបញ្ហាកើតឡើង។

- ផ្លូវមួយចំនួនតូចនៅក្នុងខណ្ឌមិនទាន់មានលក្ខណៈល្អប្រសើរនៅឡើយ ដូចជាទឹកលិចផ្លូវពេលមានភ្លៀងខ្លាំងម្តងៗ និងពិបាកធ្វើដំណើរ។
- មានចំណុចខ្លះៗដូចជាបញ្ហាក្មេងទំនើងសេបគប់គ្រឿងញៀន និងក្មេងអនាថាដែលធ្វើឱ្យប៉ះពាល់ដល់អារម្មណ៍ភ្ញៀវទេសចរណ៍ និងសង្គម។
- មន្ត្រីមួយចំនួននៅតាមសង្កាត់មិនបានដឹង អំពីព័ត៌មានផ្សេងៗដែលស្ថិតក្រោមដែនសម្ថកិច្ចរស់ខ្លួន។ ការផ្តល់ព័ត៌មានរបស់សង្កាត់មួយចំនួនតូចមានលក្ខណៈមិនច្បាស់លាស់។
- នៅក្នុងខណ្ឌមានជនអន្តោប្រវេសន៍មករស់នៅមានចំនួនច្រើន។
- មានផ្សារមួយចំនួនតូចនៅខ្វះការរៀបចំសណ្តាប់ធ្នាប់ ដែលធ្វើឱ្យកកស្ទះចរាចរណ៍

# ជំពូកទី ៥
# សេចក្តីសន្និដ្ឋាន
# និងការផ្តល់អនុសាសន៍

## ជំពូកទី ៥
## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាន៍

### ៥.១ សេចក្តីសន្និដ្ឋាន

យោងតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវ អំពីដំណើការនៃការគ្រប់គ្រងរដ្ឋបាលសាលាខណ្ឌទួលគោកនៃរាជធានីភ្នំពេញមក ក្រុមយើងខ្ញុំសង្កេតឃើញថា ការគ្រប់គ្រងរដ្ឋបាលរបស់សាលាខណ្ឌទួលគោក មានដំណើការទៅយ៉ាងល្អ និងមានសកម្មភាពរស់រវើក ទាំងសកម្មភាពនៃការងាររបស់ក្រុមប្រឹក្សាខណ្ឌ របស់គណៈអភិបាល ក៏ដូចជាសកម្មភាពរបស់មន្ត្រីដែលបម្រើការនៅក្នុងសាលាខណ្ឌទួលគោកផងដែរ។ ហើយអ្វីដែលគួរកត់សម្គាល់នោះការផ្តល់សេវាជូនដល់ប្រជាពលរដ្ឋ ដែលមកទទួលយកសេវាសាធារណៈដែលខណ្ឌផ្តល់ឱ្យ។

## ៥.២ ការផ្ដល់អនុសាសន៍

ក្រោយពីបានបញ្ចប់ការសិក្សាស្រាវជ្រាវ អំពីការគ្រប់គ្រងរដ្ឋបាលសាលាខណ្ឌទួលគោកនៃរាជធានីភ្នំពេញ ក្រុមយើងខ្ញុំបានយល់ឃើញថា ខណ្ឌទួលគោកនូវមានចំណុចខ្វះខាតមួយចំនួនដែលគួរតែពិនិត្យ និងពិចារណា កែលម្អឡើងវិញដូចតទៅ÷

- ខណ្ឌគួរតែបង្កើនសមត្ថភាពក្នុងការពិនិត្យ តាមដាន និងវាយតម្លៃសកម្មភាពការងាររបស់សង្កាត់ទាំង ១០ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខណ្ឌដើម្បីធានាកិច្ចអភិវឌ្ឍឱ្យមានប្រសិទ្ធភាព និងនិរន្តរភាព។
- សាលាខណ្ឌគួរតែរៀបចំសណ្ដាប់ធ្នាប់ជុំវិញបរិវេនសាលាខណ្ឌ ឱ្យបានល្អប្រសើរជាងនេះបន្ថែមទៀត។

- ខណ្ឌគួរតែបន្ថែមនូវមន្ត្រីទៅតាមការិយាល័យមួយចំនួនដែលខ្វះខាត
- ខណ្ឌគួរតែស្នើសុំទៅសាលាក្រុងដើម្បីបង្កើតប្រព័ន្ធ Data Bass ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងទិន្នន័យក្នុងខណ្ឌទាំងមូល។
- ខណ្ឌគួរតែស្នើសុំទៅក្រុមហ៊ុន ស៊ិន ទ្រី លើការប្រមូលសំរាមនៅតាមផ្សារនីមួយៗដែលស្ថិតក្នុងខណ្ឌរបស់ខ្លួន ពីព្រោះពេលមានភ្លៀងធ្លាក់វាធ្វើឱ្យមានក្លិនអាក្រក់នៅជុំវិញផ្សារ ក៏ដូចជាធ្វើឱ្យស្ទះចរាចរណ៍ផងដែរ។
- ក្រុមប្រឹក្សាខណ្ឌគួរអនុម័តថវិកាបន្ថែមសម្រាប់ចំណាយលើ ការជួសជុលហេដ្ឋា-រចនាសម្ព័ន្ធដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- ខណ្ឌគួរតែពង្រឹងបន្ថែមឱ្យបានល្អ នូវការការពារតាមគោលដៅនីមួយៗដែលមានស្រាប់។
- គួរតែពង្រឹងក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីបម្រើការនៅក្នុងខណ្ឌ (មន្ត្រីក្របខ័ណ្ឌ និងមន្ត្រីជាប់កិច្ចសន្យា)។

# សូមអរគុណ